វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម

នៃរាជបណ្ឌិត្យសភាកម្ពុជា


# អត្ថបទស្រាវជ្រាវ

## ស្តីពី

# «នគរូបនីយកម្មសកលលោកនិងចំណាកជនបទ»


ដោយលោក ហៃ សុគន្ធា

មន្ត្រីស្រាវជ្រាវផ្នែកភូមិវិទ្យានិងនគរូបនីយកម្ម



ខែកុម្ភៈ ឆ្នាំ២០១៩

# នគរូបនីយកម្មសកលលោកនិងចំណាកជនបទ

ដោយលោក **ហៃ សុគន្ធា**
មន្ត្រីស្រាវជ្រាវផ្នែកភូមិវិទ្យានិងនគរូបនីយកម្ម

## ១- សេចក្តីផ្តើម

ក្នុងន័យទូទៅ នគរូបនីយកម្មគឺសំដៅទៅលើការផ្លាស់ប្តូរចំនួនប្រជាជនពីទីជនបទទៅទីប្រជុំជននៅក្នុងប្រទេសនីមួយៗ ដែលជាហេតុបណ្តាលឱ្យមានរីករាលដាលទាំងទំហំ ទ្រង់ទ្រាយ និងទីតាំងភូមិសាស្ត្រ ជាដើម នៃតំបន់ទីប្រជុំជននោះ។ ដំណើរការរៀបចំនិងអភិវឌ្ឍទីក្រុងនិងទីប្រជុំជន គឺកើតឡើងដោយសារតម្រូវការនានារបស់មនុស្សដែលមានវត្តមាននៅទីនោះ ពោលគឺការបង្កើនល្បឿនលើគ្រប់វិស័យ។ ទោះបីជាមានការកំណត់ដោយឡែកៗពីគ្នារវាងប្រទេសនីមួយៗយ៉ាងណាក៏ដោយ ក៏ការធ្វើនគរូបនីយកម្មត្រូវបានកត់សម្គាល់ក្នុងន័យរួមមួយ គឺការរីកចម្រើនរបស់ទីក្រុងឬទីប្រជុំជន។ តាមរបាយការណ៍អង្គការសហប្រជាជាតិបានបង្ហាញថា ជិតពាក់កណ្តាលនៃប្រជាជនពិភពលោករស់នៅក្នុងតំបន់ទីក្រុងនិងទីប្រជុំជននាដំណាច់ឆ្នាំ២០០៨ ហើយគេបានព្យាករណ៍ទៀតថា នៅដំណាច់ឆ្នាំ២០៥០ ប្រជាជនប្រហែល៦៤% នៅក្នុងប្រទេសកំពុងអភិវឌ្ឍ និងប្រមាណជា៨៦% នៃប្រជាជននៅក្នុងប្រទេសអភិវឌ្ឍន៍នឹងត្រូវធ្វើចំណាកជនបទទៅទីក្រុងឬទីប្រជុំជន ឬក៏អាចធ្វើនគរូបនីយកម្មតំបន់តែម្តង ពោលគឺ មានប្រជាជនប្រមាណជា៣ពាន់លាន់រស់នៅទីក្រុងនិងទីប្រជុំជន ជាពិសេសគឺការកើតឡើងនៅក្នុងទ្វីបអាហ្វ្រិកនិងអាស៊ី។ ជាងនេះទៀត តាមរបាយការណ៍អង្គការសហប្រជាជាតិដដែលបានព្យាករណ៍ថា កំណើនប្រជាជនស្ទើរតែទាំងអស់នៅក្នុងពិភពលោកចាប់ពីឆ្នាំ២០១៧ដល់ឆ្នាំ២០៣០ នឹងត្រូវបានស្រូបយកដោយទីក្រុងនិងទីប្រជុំជន ដែលមានប្រជាជនចំនួនប្រមាណជា ១,១លាននាក់ក្នុងរយៈពេលប្រមាណ១៣ឆ្នាំខាងមុខ។

ការធ្វើនគរូបនីយកម្ម គឺពាក់ព័ន្ធទៅនឹងកត្តាផ្សេងៗទៀតជាច្រើន ដូចជា ការរៀបចំទីក្រុងទីក្រុង ការសិក្សាភូមិសាស្ត្រ ការសិក្សាវិភាគសង្គមវិទ្យា សេដ្ឋកិច្ច និងសុខភាពសាធារណៈ។ ការធ្វើនគរូបនីយកម្មអាចត្រូវបានគេកំណត់បរិមាណនៃការអភិវឌ្ឍទីក្រុងដោយផ្អែកលើចំនួនប្រជាជនសរុបឬជាអត្រា ដែលអត្រាប្រជាជននៅតាមទីប្រជុំជនកំពុងកើនឡើង។ ជាការពិត នគរូបនីយកម្មបានបង្កើតនូវការផ្លាស់ប្តូរសង្គមសេដ្ឋកិច្ចនិងបរិស្ថាន ដែលផ្តល់នូវឱកាសសម្រាប់និរន្តភាពជាមួយនឹង «សក្តានុពលក្នុងការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព ដើម្បីបង្កើតឱ្យមានការប្រើប្រាស់ដីធ្លីប្រកបដោយនិរន្តភាពនិងដើម្បីការពារជីវចម្រុះនៃប្រព័ន្ធអេកូធម្មជាតិ»។ នគរូបនីយកម្មមិនមែនគ្រាន់តែជាបាតុភូតសម័យទំនើបនោះទេ ប៉ុន្តែវាជាការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនិងជាប្រវត្តិសាស្ត្រនៃឫសសង្គមរបស់មនុស្សទូទាំងពិភពលោក ដែលវប្បធម៌ភាគច្រើននៅតាមជនបទ

ត្រូវបានជំនួសយ៉ាងឆាប់រហ័សដោយវប្បធម៌ទីក្រុង។ ការផ្លាស់ប្តូរដ៏ធំបំផុតដំបូងនៃគំរូតាំងទីលំនៅ គឺការប្រមូលផ្តុំអ្នកប្រមូលសត្វព្រៃចូលក្នុងភូមិរាប់ពាន់ឆ្នាំមកហើយ។ វប្បធម៌នៅតាមភូមិដ្ឋានជនបទ ត្រូវបានកំណត់ដោយសារទំនាក់ទំនងយ៉ាងជិតស្និទ្ធនិងអាកប្បកិរិយារួមគ្នា ចំណែកឯវប្បធម៌នៅតាមទីក្រុងនិងទីប្រជុំជនអាចត្រូវបានកំណត់ដោយសារខ្សែបន្ទាត់កាត់ផ្តាច់ណាមួយ ឬដោយសារការមានទំនាក់ទំនងមិនសូវច្បាស់លាស់និងឥរិយាបថបែបប្រកួតប្រជែង។

## ២- ប្រវត្តិនគរូបនីយកម្ម

ចាប់តាំងពីការបង្កើតទីក្រុងដំបូងបង្អស់នៅមេសូប៉ូតាមៀ និងរហូតមកដល់សតវត្សរ៍ទី១៨ គេសង្កេតឃើញ លំនឹងរវាងប្រជាជនភាគច្រើនដែលបានចូលរួមក្នុងវិស័យកសិកម្មដើម្បីចិញ្ចឹមជីវិតនៅក្នុងបរិបទជនបទ និងមជ្ឈមណ្ឌលពាណិជ្ជកម្មតូចៗនៅតាមទីប្រជុំជនដែលជាសកម្មភាពសេដ្ឋកិច្ច និងពាណិជ្ជកម្មនៅតាមទីផ្សារ។ ដោយសារតែស្ថានភាពនៃកសិកម្មនៅដំណាក់កាលដំបូងនិងមិនជាប់គាំងនៅក្នុងអំឡុងពេលនេះ អត្រាសមាមាត្រនៃប្រជាជននៅតាមជនបទនិងទីក្រុងនៅតែមានលំនឹងថេរ។ ទោះជាយ៉ាងណាក៏ដោយ ក៏ការកើនឡើងគួរឱ្យកត់សម្គាល់នៃភាគរយប្រជាជនទីក្រុងនៅទូទាំងពិភពលោក អាចត្រូវបានរកឃើញនៅសហវត្សរ៍ទី១មុនគ.ស.។ ការកើនឡើងគួរឱ្យកត់សម្គាល់មួយផ្សេងទៀត ត្រូវបានរកឃើញនៅ Mughal ប្រទេសឥណ្ឌាដែលមានប្រជាជនប្រមាណជា១៥% រស់នៅក្នុងទីក្រុងក្នុងអំឡុងសតវត្សរ៍ទី១៦និង១៧ ពោលគឺមានអត្រាខ្ពស់ជាងនៅទ្វីបអឺរ៉ុប ដែលមានប្រជាជនប្រមាណជា៨%-១៣% ប៉ុណ្ណោះនាពេលនោះ។

ជាមួយនឹងការចាប់ផ្តើមនៃបដិវត្តន៍កសិកម្មនិងឧស្សាហកម្មអង់គ្លេសនៅចុងសតវត្សរ៍ទី១៨ ចំនួនទាំងនេះត្រូវបានផ្លាស់ប្តូរជាគំហុក ពោលគឺការតាំងទីលំនៅដែលមិនធ្លាប់មានពីមុននៅក្នុងទីក្រុងនិងទីប្រជុំជនបានកើតឡើងយ៉ាងឆាប់រហ័សនៅសតវត្សរ៍ទី១៩ រួមទាំងតាមរយៈការបន្តការធ្វើចំណាកស្រុកពីជនបទផង និងដោយសារតែភាពរឹងមាំនៃការពង្រីកប្រជាសាស្ត្រដែលបានកើតឡើងនៃតំបន់ទីក្រុងនិងទីប្រជុំជននៅគ្រានោះផង។ នៅក្នុងប្រទេសអង់គ្លេសនិងប្រទេសវែល ចំនួនប្រជាជនដែលរស់នៅក្នុងទីក្រុងនិងទីប្រជុំជនបានកើតឡើងដល់១៧% នៅដើមសតវត្សរ៍ទី១៩ និងរហូតដល់៥៤% នៅចុងសតវត្សរ៍ទី១៩។ លក្ខណៈបែបនេះក៏មិនសូវខុសគ្នាដែរទៅនឹងប្រទេសមួយចំនួនផ្សេងទៀតក្នុងការធ្វើនគរូបនីយកម្ម ដូចជាប្រទេសបារាំង ប្រមាណជា៣៧% នៅក្នុងទីក្រុងនិងទីប្រជុំជន និងសហរដ្ឋអាម៉េរិកប្រមាណជា២៨% រស់នៅតំបន់ទីក្រុងនិងទីប្រជុំជន។

នគរូបនីយកម្មបានរីករាលដាលយ៉ាងឆាប់រហ័សនៅទូទាំងពិភពលោក ជាពិសេសប្រទេសលោកខាងលិច ប៉ុន្តែចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៥០មក នគរូបនីយកម្មបានចាប់ផ្តើមរីករាលដាលយ៉ាងខ្លាំងនៅក្នុងប្រទេសកំពុងអភិវឌ្ឍផងដែរ។ ជាក់ស្តែងនៅចុងសតវត្សរ៍ទី២០ មានប្រជាជននៅក្នុងពិភពលោកប្រមាណតែ១៥% ប៉ុណ្ណោះរស់នៅក្នុងទីក្រុងនិងទីប្រជុំជនភាគច្រើនប្រទេសអភិវឌ្ឍន៍ ប៉ុន្តែតួលេខនេះត្រូវបានប្រែប្រួលរហូតដល់ប្រមាណជា៥០% នៅឆ្នាំ២០០៧(ដើមសតវត្សរ៍ទី២១) ដោយសារការកើនឡើងយ៉ាងគំហុករបស់ប្រទេសកំពុងអភិវឌ្ឍជាពិសេសទ្វីបអាស៊ីនិងអាហ្វ្រិក។




ការព្យាការណ៍ចំនួនប្រជាជនជនបទនិងទីក្រុងឆ្នាំ២០៥០(UNFPA)

## ៣- មូលហេតុនគរូបនីយកម្ម

ការធ្វើនគរូបនីយកម្ម គឺជាកើតឡើងនៃការរៀបចំផែនការដែលជាលទ្ធផលនៃសកម្មភាពរួមគ្នារវាងឯកជននិងរដ្ឋ។ ការរស់នៅក្នុងទីក្រុងឬទីប្រជុំជនអាចមានអត្ថប្រយោជន៍ផ្នែកវប្បធម៌និងសេដ្ឋកិច្ចច្រើនជាងជនបទ ដោយសារវាអាចផ្តល់នូវឱកាសច្រើនក្នុងការទទួលបានទីផ្សារការងារ ការកាត់បន្ថយពេលវេលា កាត់បន្ថយការចំណាយក្នុងការធ្វើដំណើរនិងការដឹកជញ្ជូន ការធ្វើឱ្យប្រសើរនូវលក្ខខណ្ឌលំនៅដ្ឋាននិងលក្ខខណ្ឌសុវត្ថិភាព។ លក្ខខណ្ឌជាច្រើន ដូចជាដង់ស៊ីតេ ភាពចម្រុះនានា និងការប្រកួតប្រជែងទីផ្សារ គឺជាធាតុផ្សំនៃបរិយាកាសទីក្រុងឬទីប្រជុំជនដែលអាចនាំទៅដល់ភាពវិជ្ជមានសម្រាប់ទីក្រុងឬទីប្រជុំជននោះ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ភាពអវិជ្ជមានតែតែកើតមានជានិច្ច ក្នុងការផ្លាស់ប្តូរនិងបង្កើនតម្លៃនៃការរស់នៅដើម្បីផ្សារភ្ជាប់ទៅនឹងអ្វីដែលហៅថាបទដ្ឋាននៃការរស់នៅតាមទីក្រុង។ ជាក់ស្តែង តំបន់ជាយក្រុងនានាដែលកំពុងកើតមានឡើងនៅក្នុងទីក្រុងនៃបណ្តាប្រទេសកំពុងអភិវឌ្ឍធំៗ អាចត្រូវបានចាត់ទុកថា គឺជាការធ្វើឱ្យមានតុល្យភាពនៃទិដ្ឋភាពអវិជ្ជមាននៃជីវិតទីក្រុងខណៈពេលដែលមានការប្រើប្រាស់ធនធានរួមនិងស្មើភាព។

នៅចុងសតវត្សរ៍ទី២០និងដើមសតវត្សរ៍ទី២១ មនុស្សជាច្រើនបានផ្លាស់ទីលំនៅទៅទីក្រុង ដើម្បីទទួលបានឱកាសសេដ្ឋកិច្ច ជាពិសេសប្រទេសចិននិងឥណ្ឌា ក៏ប៉ុន្តែការផ្លាស់ទីទាំងនេះ គឺមិនបានបង្ហាញជារូបភាពលម្អិតនៃការធ្វើនគរូបនីយកម្មដែរ។ នៅតំបន់ជនបទ កសិដ្ឋានគ្រួសារតូចៗឬកសិដ្ឋានប្រមូលផ្តុំនៅតាមភូមិនានា ពិតជាមានការលំបាកក្នុងការប្រើប្រាស់ទំនិញដែលផលិតនៅតាមទីក្រុង ទោះបីជាគុណភាពជីវិតទូទៅមានលក្ខណៈជាប់ទាក់ទងគ្នាយ៉ាងពិតប្រាកដជាមួយនឹងទីក្រុងក៏ដោយ។ ម្យ៉ាងវិញទៀត ការរស់នៅតាមកសិដ្ឋាននៅជនបទ តែងតែងាយនឹងជួបប្រទះគ្រោះធម្មជាតិដែលមិនអាចទាយទុកជាមុនបានឡើយ ដូចជានៅពេលខ្លះមានគ្រោះរាំងស្ងួត គ្រោះទឹកជំនន់ ឬជំងឺអាសន្នរោគជាដើម ដែលជាហេតុធ្វើឱ្យការរស់រានមានជីវិតនៅតាមជនបទអាចនឹងជួបបញ្ហា។ បទពិសោធន៍នៅក្នុងប្រទេសថៃ ការធ្វើនគរូបនីយកម្មក៏ជាលទ្ធផលនៃការកើនឡើងបញ្ហាជាច្រើននៅតាមជនបទដែរ ដូចជាការផ្លាស់ប្តូរពីបរិយាកាសជនបទមកសហគមន៍ជនបទ ក៏អាចបណ្តាលឱ្យមានការផ្លាស់ប្តូររបបអាហារជាមូលដ្ឋាន ដែលផ្អែកទៅលើរបបអាហារដែលជីវិតជនបទមិនធ្លាប់ទទួលបាននិងអនុវត្ត។

ទីក្រុងនិងទីប្រជុំជន គឺជាកន្លែងដែលផ្តល់ជូននូវសេវាកម្មជាច្រើនរួមទាំងសេវាកម្មជំនាញដែលមិនមាននៅក្នុងតំបន់ជនបទ។ សេវាកម្មទាំងនេះ តម្រូវឱ្យកម្មករនិយោជិតធ្វើឱ្យមានឱកាសការងារកាន់តែច្រើននិង

មានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។ មនុស្សវ័យចំណាស់អាចត្រូវបានបង្ខំឱ្យផ្លាស់ទីលំនៅទៅកាន់ទីក្រុងនានាដែលមានវេជ្ជបណ្ឌិតនិងមន្ទីរពេទ្យដែលអាចបំពេញតម្រូវការសុខភាពរបស់ពួកគេ រួមទាំងឱកាសសិក្សាដែលមានគុណភាពខ្ពស់ គឺជាកត្តាមួយផ្សេងទៀតមាននៅក្នុងទីក្រុង។

## ៤. កត្តាប្រឈមនៃនគរូបនីយកម្ម

### ៤.១. ផលប៉ះពាល់សេដ្ឋកិច្ច

នៅពេលទីក្រុងមានការរីកចម្រើន ផលប៉ះពាល់ជាច្រើននឹងកើតមានឡើង រួមបញ្ចូលទាំងការកើនឡើងយ៉ាងខ្លាំងនិងការប្រែប្រួលថ្លៃដើមរបស់ទំនិញនានានៅក្នុងទីផ្សារផងដែរ ជាពិសេសប្រទេសកំពុងអភិវឌ្ឍដែលកើតមានឡើងនូវវិសមភាពជាច្រើនដោយសារនិន្នាការនគរូបនីយកម្មយ៉ាងឆាប់រហ័ស។ ការជំរុញឱ្យមានការរីកចម្រើននៅក្នុងទីក្រុងឬទីប្រជុំជនយ៉ាងឆាប់រហ័ស អាចនាំឱ្យកើតមាននូវប្រសិទ្ធភាពប្រកបទៅដោយសមធម៌តិចតួច។ បញ្ហាមួយនៅក្នុងចំណោមបញ្ហាជាច្រើននៅក្នុងការអភិវឌ្ឍទីក្រុង គឺកម្មករប្រវេសន៍ជាច្រើនធ្វើចំណាកស្រុកពីទីជនបទ និងកម្មករអន្តោប្រវេសន៍ចំណាកប្រទេសជាច្រើន ដែលជាកត្តាធ្វើឱ្យមានកំណើនតំបន់អនាធិបតេយ្យនៅក្នុងទីក្រុងឬទីប្រជុំជនដែលកំពុងធ្វើនគរូបនីយកម្មនោះតែម្តង។ មានករណីជាច្រើនទៀត កម្មករប្រវេសន៍និងអន្តោប្រវេសន៍ដែលមានជំនាញតិចតួចឬគ្មានជំនាញ រស់នៅក្នុងទីក្រុងដែលសំបូរទៅឱកាសសេដ្ឋកិច្ច តែពួកគាត់នៅតែគ្មានឱកាសការងារនិងមិនមានលទ្ធភាពអាចរកការងារធ្វើ ជាហេតុធ្វើពួកគាត់គ្មានលទ្ធភាពក្នុងការស្វែងរកលំនៅដ្ឋានសមរម្យនៅតាមទីក្រុងបានទេ ហើយត្រូវបង្ខំចិត្តរស់នៅក្នុងតំបន់អនាធិបតេយ្យនៅក្នុងទីក្រុង។ បញ្ហាទីប្រជុំជននិងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ក៏កំពុងតែជំរុញឱ្យមាននិន្នាការនគរូបនីយកម្ម ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍនានា ទោះបីជាទីក្រុងសំខាន់ៗនៅក្នុងប្រទេសមាននិន្នាការនគរូបនីយកម្មក៏ដោយ ក៏ទីប្រជុំជននៅតែបន្តលក្ខណៈនេះកាន់តែច្រើនជាងមុន។ ការធ្វើនគរូបនីយកម្មនិងហេដ្ឋារចនាសម្ព័ន្ធទីក្រុងមួយញឹកញាប់ ត្រូវបានគេមើលឃើញថាមានផលប៉ះពាល់ច្រើន ប៉ុន្តែភាពអវិជ្ជមានទាំងនេះ គឺជាកត្តាចម្បងក្នុងការនាំទៅដល់ការកាត់បន្ថយការចំណាយក្នុងការធ្វើដំណើរនិងការដឹកជញ្ជូនខណៈពេលដែលការកែលម្អឱកាសសម្រាប់ការងារអប់រំ និងការស្នាក់នៅត្រូវបានអភិវឌ្ឍបន្តបន្ទាប់។

ប្រទេសកំពុងអភិវឌ្ឍជាច្រើនដែលមានកំណើនសេដ្ឋកិច្ចកំពុងរីកដុះដាល និងការកើនឡើងយ៉ាងគំហុកលើវិស័យឧស្សាហកម្មធុនស្រាលមួយចំនួន បានធ្វើឱ្យប្រជាជនវ័យក្មេងភាគច្រើននៅក្នុងប្រទេសទាំងនេះជួបឧបសគ្គ ដូចជាកង្វះខាតលទ្ធភាពក្នុងការទទួលបានសេវាហិរញ្ញវត្ថុនិងសេវាពិគ្រោះអាជីវកម្ម ការលំបាកក្នុងការទទួលបានឥណទានដើម្បីចាប់ផ្តើមអាជីវកម្ម និងខ្វះជំនាញសហគ្រិនដើម្បីប្រឹក្សាឱ្យពួកគេអាចទទួលបានឱកាសនៅក្នុងឧស្សាហកម្មទាំងនេះ។ ការវិនិយោគលើធនធានមនុស្ស ដើម្បីឱ្យមនុស្សវ័យក្មេងមានលទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាព និងកាយសម្បទាគ្រប់គ្រាន់ដើម្បីទទួលបាននូវសម្ភារៈបរិក្ខារអប់រំ គឺជាការចាំបាច់ដើម្បីយកឈ្នះលើបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចនៅក្នុងការធ្វើនគរូបនីយកម្ម។

### ៤.២. ផលប៉ះពាល់បរិស្ថាន

ទីក្រុងនៃប្រទេសនៅក្នុងតំបន់ត្រូពិក គឺជាទីក្រុងដែលមានសីតុណ្ហភាពខ្ពស់ ហើយវាបានក្លាយទៅជាកង្វល់រួមនៃការកើនឡើងកម្តៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ កម្តៅនៅក្នុងទីក្រុងនានា បានកើនឡើងខ្ពស់នៅពេលដែលវិស័យឧស្សាហកម្មកាន់រីកចម្រើន។ យានយន្ត រោងចក្រ និងឧបករណ៍កំដៅនៃផលិតផលឧស្សាហកម្មផ្សេងទៀត បានបញ្ចេញសារធាតុផ្សេងៗទៅក្នុងបរិយាកាស ដែលជាហេតុធ្វើឱ្យទីក្រុងជាទូទៅមាន

សីតុណ្ហភាពចាប់ពី១°C ទៅ ៣°C ក្តៅជាងតំបន់ដែលនៅជុំវិញ។ ផលប៉ះពាល់ក៏រួមបញ្ចូលទាំងការកាត់បន្ថយសំណើមដីនិងការកាត់បន្ថយការបញ្ចេញចោលកាបូនឌីអុកស៊ីតឡើងវិញ។ តាមលោក Stewart Brand បានអះអាងថា ផលប៉ះពាល់អំពីការធ្វើនគរូបនីយកម្មគឺមានភាពអវិជ្ជមានចំពោះបរិស្ថាន។ ទី១ អត្រាកំណើននៃអ្នករស់នៅតាមទីក្រុងនិងប្រជុំជនកើនឡើងឬរក្សានូវអត្រាមិនប្រែប្រួលណាមួយ ដែលនៅតែអាចឈានទៅរកភាពតានតឹងផ្នែកបរិស្ថានដោយសារកំណើនប្រជាជន។ ទី២ ការធ្វើចំណាកស្រុកចេញពីតំបន់ជនបទបានធ្វើឱ្យមានការបាត់បង់បច្ចេកទេសធ្វើកសិកម្មចិញ្ចឹមជីវិតខ្លះ ដែលឈានទៅដល់ការបំផ្លិចបំផ្លាញ ដូចជាការកាប់សម្លាប់និងដុតបំផ្លាញវិស័យកសិកម្មជាដើម។ តាមរបាយការណ៍របស់អង្គការសហប្រជាជាតិឆ្នាំ២០១៣ បានព្រមានថា ជាមួយនឹងប្រជាជនប្រមាណជាង២,៤ពាន់លាននាក់នៅជនបទគិតត្រឹមឆ្នាំ២០៥០ បរិមាណម្ហូបអាហារដែលផលិតបាននឹងត្រូវកើនឡើងប្រហែល៧០% ដែលអាចរាំងស្ទះដល់ការផលិតស្បៀងអាហារ ហើយមានប្រទេសខ្លះនៅក្នុងពិភពលោកបានកំពុងនឹងប្រឈមអសន្តិសុខស្បៀងរួចទៅហើយ ដោយសារតែការផ្លាស់ប្តូរស្ថានភាពបរិស្ថាន។ ម៉្យាងទៀត ការផ្លាស់ប្តូរបែបនេះ អាចនឹងធ្វើឱ្យប្រព័ន្ធអនាម័យនិងការថែទាំសុខភាពសាធារណៈមានភាពតានតឹង ហើយអាចបង្កឱ្យមានគ្រោះមហន្តរាយផ្នែកមនុស្សធម៌និងបរិស្ថាន។

**ក. គុណភាពទឹក**

ការកើតឡើងនៃ eutrophication នៅក្នុងទឹក គឺជាផលប៉ះពាល់មួយផ្សេងទៀតទៅដល់ចំនួនប្រជាជនទីក្រុងលើបរិស្ថាន។ នៅពេលមានភ្លៀងធ្លាក់នៅតាមបណ្តាទីក្រុងធំៗ ទឹកភ្លៀងអាចជួយបំផ្លាញសារធាតុពុលដូចជាឧស្ម័នកាបូនិកនិងឧស្ម័នផ្ទះកញ្ចក់ដទៃទៀតនៅលើអាកាសទៅលើដីខាងក្រោម បន្ទាប់មកសារធាតុគីមីទាំងនេះត្រូវលាងដោយផ្ទាល់ ហើយបង្កឱ្យមានការថយចុះគុណភាពទឹកនិងបំផ្លាញប្រព័ន្ធអេកូឡូហ្ស៊ី។ ផ្ទៃមហាសមុទ្រក៏មានសមត្ថភាពក្នុងការស្រូបយកឧស្ម័នកាបូនិក ដែលភាយចេញពីបរិយាកាសផែនដីនៅពេលដែលការបញ្ចេញឧស្ម័នកើនឡើងជាមួយនឹងការកើនឡើងនៃនគរូបនីយកម្ម។ តាមការសិក្សាស្រាវជ្រាវបង្ហាញថា មហាសមុទ្រស្រូបយក ១/២ នៃ$CO_2$ ដែលផលិតដោយមនុស្ស និងមានប្រយោជន៍ដល់បរិស្ថាន ក្នុងការជួយកាត់បន្ថយផលប៉ះពាល់នៃឧស្ម័នផ្ទះកញ្ចក់ ប៉ុន្តែវាបានបង្កឱ្យមានអាស៊ីដផងដែរ។

**ខ. កាកសំណល់ចំណីអាហារ**

ការរីកចម្រើនយ៉ាងឆាប់រហ័សនៃសហគមន៍ បានបង្កើតនូវបញ្ហាប្រឈមថ្មីៗ ជាពិសេសនៅក្នុងប្រទេសអភិវឌ្ឍន៍ ហើយបញ្ហាប្រឈមមួយគឺការកើនឡើងនូវកាកសំណល់អាហារ ដែលត្រូវបានគេស្គាល់ថាជាកាកសំណល់ម្ហូបអាហារទីក្រុង។ កាកសំណល់អាហារ គឺជាការបោលផលិតផលម្ហូបអាហារដែលមិនអាចយកមកប្រើប្រាស់បានទៀតទេ ដោយសារតែផលិតផលទាំងនោះផុតកំណត់ឬខូចគុណភាព។ ការបង្កើនកាកសំណល់ម្ហូបអាហារ អាចបង្កើនការព្រួយបារម្ភខាងផ្នែកបរិស្ថាន ដូចជាបង្កើនការផលិតឧស្ម័នមេតាន និងការបង្កឱ្យមានប្រភេទជំងឺផ្សេងៗ។ កន្លែងចាក់សំរាមគឺជាមូលហេតុនាំមុខគេទី៣ នៃការភាយចេញមេតាន ដែលបណ្តាលឱ្យមានការព្រួយបារម្ភលើផលប៉ះពាល់របស់វាចំពោះអូហ្សូននិងសុខភាពរបស់មនុស្ស។ កាកសំណល់អាហារច្រើនសន្ធឹកសន្ធាប់បណ្តាលឱ្យកើតមានឡើងនូវជាតិ fermentation ដែលបង្កើនជាហានិភ័យផ្សេងៗ ដូចជាបង្កើតសត្វចម្លងមេរោគនិងសត្វល្អិតផ្សេងទៀត។

**គ. ទីជម្រកនិងជីវៈចម្រុះ**

ការធ្វើនគរូបនីយកម្ម អាចជះឥទ្ធិពលយ៉ាងធំធេងលើជីវៈចម្រុះដោយសារការបង្កឱ្យមានការបែងចែកជម្រកនិងការបាត់បង់ពូជពង្សដែលត្រូវបានគេស្គាល់ថាជាការបែងចែកទីជម្រក។ ការបែកបាក់ឬបាត់បង់លំនៅ

ដ្ឋាន មិនប្រាកដថាជាការបំផ្លាញទីជម្រកនោះទេ ប៉ុន្តែវាអាចបំបែកដាច់ដោយឡែកទៅជាផ្លូវថ្នល់និងផ្លូវដែក។ ទម្រង់នៃការផ្លាស់ប្តូរបែបនេះ អាចប៉ះពាល់ទៅដល់ទីជម្រកនៃជីវៈចម្រុះផ្សេងៗ ក្នុងការទ្រទ្រង់ជីវិតដោយបំបែកចេញពីបរិស្ថាន ពោលគឺភាពងាយស្រួលក្នុងការរកអាហារនិងរកកន្លែងដែលពួកវាអាចលាក់ខ្លួនពីការធ្វើនគរូបនីយកម្ម។ ការរៀបចំផែនការនិងការគ្រប់គ្រងឱ្យបានត្រឹមត្រូវក្នុងធ្វើនគរូបនីយកម្ម គឺជាកាត់បន្ថយនូវផលប៉ះពាល់ទាំងឡាយ មិនថាជីវិតមនុស្សឬសត្វទេ ពោលគឺការបន្ថែមច្រករបៀងផ្សេងៗនៃទីប្រជុំជនដើម្បីជួយសម្រួលក្នុងការកែទម្រង់នៃនគរូបនីយកម្មទីក្រុងនីមួយៗ។

## ៤.៣ សុខុមាលភាពនិងសង្គម

នៅក្នុងប្រទេសកំពុងអភិវឌ្ឍ នគរូបនីយកម្មមិនបានធ្វើអាយុសង្ឃឹមរស់នៃប្រជាជនប្រទេសនោះមានភាពប្រសើរឡើងនោះទេ។ ការធ្វើនគរូបនីយកម្មយ៉ាងឆាប់រហ័សបាននាំឱ្យមានការកើនឡើងនូវអត្រាស្លាប់ខ្ពស់ដោយសារជំងឺឆ្លងដែលទាក់ទងទៅនឹងរបៀបរស់នៅ រួមទាំងជំងឺមហារីកនិងជំងឺបេះដូងផងដែរ។ ភាពខុសគ្នានៃអត្រាមរណភាពដោយសារជំងឺឆ្លងអាចប្រែប្រួលអាស្រ័យលើជំងឺនិងទីតាំងជាក់លាក់។ កម្រិតសុខភាព ទីក្រុងមានភាពល្អប្រសើរបើធៀបនឹងតំបន់ជនបទ ទោះជាយ៉ាងណាក៏ដោយអ្នករស់នៅក្នុងតំបន់ក្រីក្រ ដូចជាតំបន់អនាធិបតេយ្យនិងតំបន់លំនៅដ្ឋានក្រៅផ្លូវការ នៅតែទទួលរងការគំរាមកំហែងពីជំងឺផ្សេងៗ ការស្លាប់មុនអាយុ និងកត្តាប្រឈមផ្នែកសុខភាពនិងភាពក្រីក្រ។ ប្រជាជនក្រីក្រភាគច្រើននៅតាមទីប្រជុំជនមានការលំបាកក្នុងការប្រើប្រាស់សេវាសុខាភិបាលដោយសារតែពួកគេមិនមានលទ្ធភាពចំណាយប្រាក់សម្រាប់សេវានោះ ដែលហេតុធ្វើឱ្យពួកគេងាកទៅរកអ្នកផ្តល់សេវាដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់និងគ្មានច្បាប់។ ខណៈពេលនគរូបនីយកម្មត្រូវបានផ្សារភ្ជាប់ជាមួយនឹងភាពប្រសើរឡើងនៃអនាម័យសាធារណៈ និងការទទួលបានការថែទាំសុខភាពក៏ដោយ ក៏វាតម្រូវឱ្យមានការផ្លាស់ប្តូរនៅក្នុងមុខរបរចំណីអាហារនិងលំហាត់ប្រាណដែលអាចមានឥទ្ធិពលជាច្រើនលើផ្នែកសុខភាព ដូចជា៖

### ក. អាហាររូបត្ថម្ភ

មនុស្សជិត២៣,៥លាននាក់ កំពុងរស់នៅក្នុងសហរដ្ឋអាម៉េរិកខ្វះលទ្ធភាពទទួលបានផ្សារទំនើបក្នុងចម្ងាយតែ១ម៉ាយពីផ្ទះរបស់ពួកគេ។ ការសិក្សាជាច្រើនបានបង្ហាញថា ចម្ងាយឆ្ងាយចំពោះហាងលក់គ្រឿងទេសផ្សេងៗក៏ត្រូវបានផ្សារភ្ជាប់ជាមួយនឹងអត្រាខ្ពស់នៃភាពប្រសើរផ្នែកសុខភាពដែរ។ ការធ្វើនគរូបនីយកម្ម ត្រូវបានបង្ហាញថា បានផ្សារភ្ជាប់ជាមួយនឹងការប្រើប្រាស់ផ្លែឈើស្រស់ បន្លែ គ្រាប់ធញ្ញជាតិផ្សេងៗ និងការទទួលទានចំណីអាហារកែច្នៃនិងភេសជ្ជៈជាដើម។ ហាងម្ហូបអាហារជាច្រើននៅក្នុងសហរដ្ឋអាម៉េរិក ត្រូវបានរកឃើញជាទូទៅនៅក្នុងសង្កាត់អាម៉េរិកអាហ្វ្រិកដែលប្រជាជនមានប្រាក់ចំណូលទាប ហើយការសិក្សាមួយទៀតបានរកឃើញថា ជនជាតិភាគតិចនៅក្នុងសង្កាត់ដែលមានប្រាក់ចំណូលទាបទាំងនេះ មានអត្រាកំណើនកុមារនិងកំណើតថ្មីខ្ពស់ ហើយអត្រាកំណើតថ្មីទាំងនេះ បានផ្សារភ្ជាប់ជាមួយនឹងហានិភ័យនៃកង្វះអាហាររូបត្ថម្ភនៃការធ្វើនគរូបនីយកម្ម។

### ខ. ជំងឺហឺត

ការធ្វើនគរូបនីយកម្មក៏ត្រូវបានផ្សារភ្ជាប់ជាមួយនឹងការកើនឡើងហានិភ័យនៃជំងឺហឺតផងដែរ នៅពេលដែលមានការផ្លាស់ប្តូរសហគមន៍ពីជនបទទៅសង្គមទីក្រុងកាន់តែច្រើន ចំនួនមនុស្សកាន់តែច្រើនត្រូវបាន

ប៉ះពាល់ដោយជំងឺហឺត។ នៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាបនិងមធ្យម មានកត្តាជាច្រើនដែលធ្វើឱ្យមានចំនួនខ្ពស់នៃអ្នកដែលមានជំងឺហឺត ស្រដៀងគ្នាទៅនឹងតំបន់ខ្លះនៅក្នុងសហរដ្ឋអាម៉េរិកដែលមានការរីកចម្រើននគរូបនីយកម្ម។ ផលប៉ះពាល់នៃសារធាតុពុលដែលកើតមានក្នុងខ្យល់អាកាស ដូចជាអុកស៊ីតឌីអុកស៊ីត (NO2) កាបូនម៉ូណូអុកស៊ីត(CO) និងសារធាតុតូចៗផ្សេងទៀតដែលមានអង្កត់ផ្ចិតតូចជាង២,៥មីក្រូម៉ែត្រ អាចបណ្តាលឱ្យបង្កើនហានិភ័យនៃជំងឺហឺតរបស់កុមារ។ ថ្វីបើមានការកើនឡើងនូវលទ្ធភាពទទួលបានសេវាសុខភាពតាមរយៈការកើនឡើងនៃដង់ស៊ីតេប្រជាជននៃនគរូបនីយកម្ម បានជះឥទ្ធិពលអវិជ្ជមានដល់គុណភាពខ្យល់ក្នុងបរិយាកាស ហើយនៅទីបំផុតវាបានកាត់បន្ថយតម្លៃវិជ្ជមាននៃធនធានសុខភាពនៅពេលដែលកុមារ និងមនុស្សវ័យក្មេងកាន់តែកើនឡើង ពោលគឺកើនជំងឺហឺតដោយសារអត្រាខ្ពស់នៃការបំពុលបរិយាកាស។

**គ. ឧក្រិដ្ឋកម្ម**

ការបកស្រាយដ៏សាមញ្ញបំផុតនោះ គឺថាតំបន់ដែលមានដង់ស៊ីតេប្រជាជនកាន់តែខ្ពស់ ទំនិញកាន់តែច្រើនសម្បូរបែបនិងអាចរកទិញបានដោយងាយនៅតំបន់ជុំវិញនិងក្នុងតំបន់តែម្តង ហើយការប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងតំបន់ទីក្រុងក៏អាចកើតមានឡើងបានយ៉ាងងាយដែរ ពោលគឺទំនើបកម្មអាចនាំឱ្យមានឧក្រិដ្ឋកម្មជាច្រើនផងដែរ។ ការយល់ដឹងកាន់តែច្រើនអំពីគម្លាតប្រាក់ចំណូលរវាងអ្នកមាននិងអ្នកក្រដោយសារប្រព័ន្ធផ្សព្វផ្សាយទំនើប គឺជាមូលហេតុដែលនាំឱ្យមានអារម្មណ៍ច្រណែននិងប្រកួតប្រជែងនៃការខ្វះខាតនិងលើសលប់ ដែលអាចនាំឱ្យមានបទឧក្រិដ្ឋ។ ការស្រាវជ្រាវខ្លះបានបង្ហាញថា ការកើនឡើងនៃឧក្រិដ្ឋកម្មនៅក្នុងតំបន់ទីក្រុង គឺដោយសារកត្តាប្រាក់ចំណូលរបស់មនុស្សម្នាក់ៗវិសមភាពទៅនឹងប្រាក់ចំណូលនៃប្រជាជនសរុប។

ការធ្វើចំណាកស្រុកក៏ជាកត្តាមួយដែលអាចបង្កើនឧក្រិដ្ឋកម្មនៅក្នុងតំបន់ទីក្រុងផងដែរ ដូចជាការផ្លាស់ទីលំនៅរបស់ប្រជាជនមកពីតំបន់មួយ ហើយបង្ខំឱ្យផ្លាស់ប្តូរទៅជាសង្គមនិយម។ នៅទីនេះពួកគេស្ថិតនៅក្នុងបរិយាកាសថ្មីជាមួយនឹងបទដ្ឋានថ្មីនិងតម្លៃសង្គម ដែលអាចនាំឱ្យមានការរួបរួមគ្នាជាសង្គមនិងបទឧក្រិដ្ឋកាន់តែច្រើន។ ទោះបីជានគរូបនីយកម្មមាននិន្នាការបង្កើតផលប៉ះពាល់អវិជ្ជមានក៏ដោយ ក៏ឥទ្ធិពលវិជ្ជមានមួយចំនួនបានធ្វើឱ្យនគរូបនីយកម្មបង្កើនសកម្មភាពផ្សេងៗផ្សារភ្ជាប់ជាមួយនឹងតំបន់ជនបទ។

**ឃ. សុខភាពផ្លូវចិត្ត**

កត្តានគរូបនីយកម្មដែលរួមចំណែកដល់សុខភាពផ្លូវចិត្ត អាចត្រូវបានគេគិតថាជាកត្តាដែលប៉ះពាល់ដល់បុគ្គលនិងកត្តាដែលប៉ះពាល់ដល់ក្រុមធំៗនៃសង្គម។ កត្តាម៉ាក្រូទាំងនេះរួមចំណែកដល់ភាពខុសគ្នារវាងសង្គមដែលជះឥទ្ធិពលដល់បុគ្គលតាមរយៈការបង្កើតអសន្តិសុខ ដែលអាចមើលឃើញជាបញ្ហាដោយសារបរិយាកាសខាងរាងកាយ រួមមានបញ្ហាសុវត្ថិភាពផ្ទាល់ខ្លួនឬបញ្ហាដែលទាក់ទងនឹងបរិស្ថានសង្គមដូចជាការបាត់បង់គំនិតខ្លួនឯង។ ការកើនឡើងនូវភាពតានតឹង គឺជាភាពស្មុគស្មាញខាងផ្លូវចិត្តដែលមានលក្ខណៈសាមញ្ញមួយដែលអមជាមួយនឹងការធ្វើនគរូបនីយកម្មហើយត្រូវបានគេគិតថាដោយសារតែអសន្តិសុខ។ ការផ្លាស់ប្តូរនៅក្នុងសង្គមដែលជាផលវិបាកនៃនគរូបនីយកម្ម ត្រូវបានគេគិតថានឹងនាំទៅរកការកាត់បន្ថយនូវការគាំទ្រផ្នែកសង្គម ការកើនឡើងនូវអំពើហិង្សា និងការដាក់មនុស្សច្រើនពេក។

## ៥. សេចក្តីសន្និដ្ឋាន

ទម្រង់នៃនគរូបនីយកម្មផ្សេងៗគ្នា អាចត្រូវបានចាត់ថ្នាក់ដោយអាស្រ័យលើរចនាបថនិងវិធីសាស្ត្រនៃស្ថាបត្យកម្មក្នុងការធ្វើផែនការ ក៏ដូចជាការរៀបរយកំណើនប្រជាជនជាប្រវត្តិសាស្ត្រនៃតំបន់នោះ។ នគរូបនីយកម្មនៅក្នុងទីក្រុងដែលត្រូវបានអភិវឌ្ឍជាទូទៅ គឺបង្ហាញពីការប្រមូលផ្តុំនៃសកម្មភាពរបស់មនុស្សនិងការតាំងទី

លំនៅនៅជុំវិញតំបន់ទីប្រជុំជនដែលបានមកពីការធ្វើចំណាកស្រុក។ ការធ្វើចំណាកប្រទេស(អន្តោរប្រវេសន៍) អាចសំដៅភាគច្រើនទៅលើការធ្វើចំណាកស្រុកមកពីប្រទេសអតីតសង្គមនិយម និងកន្លែងផ្សេងៗទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា។ ការរីកចម្រើនថ្មីៗនេះដូចជាគម្រោងកែលម្អទីប្រជុំជនជាដើម មានន័យថាគឺជាការមកដល់ថ្មីនៃទីក្រុងនានាដែលលែងត្រូវការលំនៅដ្ឋានអនាធិបតេយ្យ ព្រោះនៅក្នុងតំបន់អភិវឌ្ឍន៍មួយចំនួននៃទីក្រុងត្រូវបានត្រៀមលក្ខណៈជាស្រេចនៅក្នុងផែនការនគរូបនីយកម្មនៃតំបន់ទីប្រជុំជននោះ។ ទម្រង់នៃការធ្វើនគរូបនីយកម្មទាំងនេះ អាចកើតមានដោយសារទំនាក់ទំនងប្រសើរឡើងរវាងប្រជាជនទីក្រុងនិងជនបទ ប៉ុន្តែកត្តាមួយចំនួនដូចជាការភ័យខ្លាចលើផ្នែកឧក្រិដ្ឋកម្មនិងបរិស្ថានទីក្រុងក្រីក្រ វាបានរួមចំណែកទៅដល់បាតុភាពនានាដែលធ្វើឱ្យទីក្រុងធ្លាក់ចុះ រួមទាំងបទពិសោធន៍ផ្នែកឧស្សាហកម្មនៃពិភពលោកផងដែរ។

នៅពេលដែលតំបន់លំនៅដ្ឋានជាច្រើនមានការផ្លាស់ប្តូរទៅក្រោមឆ្លមណ្ឌលទីក្រុង ឬត្រូវបានគេហៅថាជាយក្រុងដែលបានកើតឡើងរហូតមកដល់ពេលនេះ គឺជាការបង្កើតចំណុចថ្មីនៃការប្រមូលផ្តុំនៅខាងក្រៅទីប្រជុំជនទាំងនៅក្នុងប្រទេសអភិវឌ្ឍន៍និងប្រទេសកំពុងអភិវឌ្ឍ។ បាតុភាពទាំងនេះ គឺជាបណ្តាញ សំណុំបែបបទ( poly-centric ) នៅក្នុងការយកចិត្តទុកដាក់ដើម្បីធ្វើជាគំរូនៃការពង្រីកនគរូបនីយកម្ម។ ជនអន្តោប្រវេសន៍ជនបទត្រូវបានទាក់ទាញដោយសារលទ្ធភាពនៃទីក្រុងដែលអាចផ្តល់ឱ្យពួកគេបាន ប៉ុន្តែជាញឹកញាប់រូបភាពទាំងនេះភាគច្រើនកើតមាននៅក្នុងតំបន់ទីក្រុងឬប្រជុំជនដែលមានភាពក្រីក្រខ្លាំង។ អសមត្ថភាពរបស់បណ្តាប្រទេសក្នុងការផ្តល់លំនៅដ្ឋានសមរម្យដល់ជនអន្តោប្រវេសន៍ដែលរស់នៅតាមជនបទ គឺពាក់ព័ន្ធទៅនឹងភាពលើសលប់នៃការធ្វើនគរូបនីយកម្ម ដែលអត្រាទាំងនេះលូតលាស់យ៉ាងឆាប់រហ័សជាងអត្រានៃការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងតំបន់ដែលនាំឱ្យមានភាពអត់ការងារធ្វើខ្ពស់និងតម្រូវការធនធានខ្ពស់។ ប្រជាជនក្រីក្រភាគច្រើននៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍមិនអាចរកការងារធ្វើបានទេ ពួកគេអាចចំណាយជីវិតរបស់ពួកគេក្នុងការងារមិនមានតម្រូវការនិងមិនមានការងារធ្វើតែម្តង។ ការធ្វើនគរូបនីយកម្មបច្ចុប្បន្ន ជាពិសេសប្រទេសអភិវឌ្ឍ អាចត្រូវគេបានរៀបចំជានគរូបនីយកម្មបែបសរីរាង្គតាមរយៈចលនាសហគមន៍ធម្មជាតិសរីរាង្គ និងចលនាទីក្រុងសួនច្បារជាដើម ដែលត្រូវបានពឹងផ្អែកទាំងស្រុងលើផែនការមេក្នុងការរៀបចំសម្រាប់ហេតុផលនយោបាយ វប្បធម៌ សង្គមសេដ្ឋកិច្ចនៃទីក្រុង។

ជាសន្និដ្ឋានការធ្វើនគរូបនីយកម្ម គឺពិតជាមិនអាចកាត់ផ្តាច់ពីចំណាកជនបទនានារបស់ប្រជាជនបានឡើយ ការសិក្សាវិភាគពីចលនាប្រវេសន៍ចូលទីក្រុងឬទីប្រជុំជន គឺជាកត្តាចម្បងដែលអ្នកសិក្សានគរូបនីយកម្មត្រូវយកចិត្តទុកដាក់ខ្ពស់។ ខណៈដែលប្រជាជនបន្តកើនឡើងនិងធ្វើនគរូបនីយកម្មក្នុងអត្រាដែលមិនធ្លាប់មានពីមុន ទីក្រុងថ្មីនិងបច្ចេកទេសនៃការរីកចម្រើនឆ្លាតវៃត្រូវបានអនុវត្តដើម្បីបង្កើតការផ្លាស់ប្តូរមួយឆ្ពោះទៅរកការអភិវឌ្ឍទីក្រុងដែលមានបរិស្ថានសេដ្ឋកិច្ចនិងសង្គមដែលមាននិរន្តរភាព។ ការរួមបញ្ចូលគ្នារវាងនិរន្តភាពនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនិងនយោបាយនៃទីក្រុងនានា គឺជាការធ្វើឱ្យមានភាពស្មើគ្នានិងភាពរឹងមាំក្នុងការអភិវឌ្ឍទីក្រុងនិងទីប្រជុំជនតាមទម្រង់នៃការអភិវឌ្ឍនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាពខ្ពស់៕

## ឯកសារយោង


- បណ្ឌិត អ៊ូ វ័ឌី *"ប្រវត្តិនគរូបនីយកម្មលើពិភពលោក"* ភ្នំពេញ ឆ្នាំ២០១២ ចំនួន ២៣៤ទំព័រ
- បណ្ឌិត បេងហុង សុជាតិ ខេមរ៉ូ "ការកសាងរៀបចំដែនដីក្នុងទីក្រុងនិងទីប្រជុំជន" អត្ថបទកសិក្ខាសាលាថ្នាក់ជាតិស្តីពី "ការរៀបចំដែនដីនិងទីក្រុង" ចំនួន ៥៩ ទំព័រ
- បណ្ឌិត បេងហុង សុជាតិ ខេមរ៉ូ *"ទំនោរនៃការវិវត្តន៍និងអភិវឌ្ឍន៍របស់ទីក្រុងនៅក្នុងព្រះរាជាណាចក្រកម្ពុជា"* វេទិកាពិភាក្សាស្តីពីភាពក្រីក្រនៅក្នុងទីក្រុង ចំនួន២៦ទំព័រ
- ប៉ែន ខុន *"ចតុមុខ"* ភ្នំពេញ ឆ្នាំ២០០១ ចំនួន ១៣៨ទំព័រ
- ក្រសួងផែនការ *"ស្ថានភាពនៃភាពក្រីក្រនៅកម្ពុជាឆ្នាំ២០១៤"* ភ្នំពេញ ឆ្នាំ២០១៦ ចំនួន ២៩ទំព័រ
- វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍកម្ពុជា *"សង្ខេបបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០០៧-២០០៨"* វ.ប.ស.អ. ភ្នំពេញ ឆ្នាំ២០០៨ ចំនួន ៦០ទំព័រ
- សាលាក្រុងភ្នំពេញ *"ផែនការយុទ្ធសាស្ត្រអភិវឌ្ឍក្រុងឆ្នាំ២០០៥-២០១៥"* ភ្នំពេញ ឆ្នាំ២០០៥ ចំនួន ៦៦ទំព័រ
- សាលាក្រុងភ្នំពេញ *"គម្រោងប្លង់គោលទីក្រុងភ្នំពេញ-យុទ្ធសាស្ត្រតម្រង់ទិស"* ភ្នំពេញ ឆ្នាំ២០០៥ ចំនួន ១៤ទំព័រ
- Abraham Eraly *"The Mughal World: Life in India's Last Golden Age"* The Penguin Books, p 5, 2007.
- Barney Cohen *"Urbanization, City Growth, and the New United Nations Development Agenda"* Cornerstone, The Official Journal of the World Coal Industry. 2015, p.4–7
- Christopher Watson *"Trends in urbanization"* Proceedings of the First International Conference on Urban Pests. 1993, CiteSeerX 10.1.1.522.7409.
- Dr. Lawrence Tseu, *Urban Transport Growth: The Challence Ahead – The new realism and Institutional Change*, Sabah-Sarawak Environmental Convention 2006, 23 p.
- Gries, T. and Grundmann R. *"Fertility and modernization: the role of urbanization in developing countries"* Journal of International Development, 2018, p.493-506
- National Library of Medicine *"Urbanization: The process whereby a society changes from a rural to an urban way of life"* USA, 5 November 2014, 326p.
- Paolo Malanima *"Pre-Modern European Economy: One Thousand Years (10th-19th Centuries)"* Brill Publisher, 2009, 244p.
- Tacoli and Cecilia *"Urbanisation: rural-urban migration and urban poverty"* London 2015 International Institute for Environment and Development 236p.
- UNFPA "Urbanization in 2013: Demographic partitions" USA, 8 July 2015, 213p.
- Urban Resource Center, *City Development Strategy for the Municipality of Phnom Penh: Study of Relocation of Urban Poor Communities in Phnom Penh,* Annual Report, March 2002, 43p.